**ផលប៉ះពាល់សង្គម និងសេដ្ឋកិច្ច**

- សិទ្ធិទទួលបានការអប់រំ ត្រូវតែបានការពារក្នុងករណីមានការបិទសាលារៀន ឧទាហរណ៍ និងប្រសិនជាអាចធ្វើទៅបាន សិក្សាតាមកម្មវិធីតាមអនឡាញ និងការចាក់ផ្សាយតាមទូរទស្សន៍ និងវិទ្យុឯកទេស។ ក្មេងស្រីអាចនឹងទទួលរងផលប៉ះពាល់ដោយមិនសមាមាត្រ ដោយហេតុថាមនុស្សជាច្រើនប្រឈមស្រាប់ហើយនូវឧបសគ្គធំៗក្នុងការទៅសាលារៀន ហើយដែលបច្ចុប្បន្ននេះ គេរំពឹងថានឹងទទួលបានកាន់តែច្រើនឡើងថែមទៀត នូវការងារនៅផ្ទះ។ ឱកាសអប់រំមានកំណត់សម្រាប់អ្នកដែលមិនមានលទ្ធភាពប្រើអ៊ិនធឺណិត និងឧបករណ៍រៀនពីចម្ងាយផ្សេងទៀត ដែលប្រឈមខ្លាំងថែមទៀតទៅនឹងវិសមភាព និងភាពក្រីក្រ។ កុមារី និងកុមារា អាចបាត់បង់លទ្ធភាពទទួលបានអាហាររូបត្ថម្ភ និងសេវាផ្សេងៗទៀតដែលសាលារៀនផ្តល់ឱ្យជារឿយៗ ដូចជា សុខភាពផ្លូវចិត្ត និងការអប់រំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។
- គម្រោងគាំពារសង្គម គួរតែយកចិត្តទុកដាក់ជាពិសេសចំពោះកុមារ ដោយសារតែពួកគេប្រឈមនឹងភាពងាយរងគ្រោះខ្ពស់ ដោយផ្អែកលើដំណាក់កាលដំបូងរបស់ពួកគេ នៃការអភិវឌ្ឍរាងកាយ បញ្ញាស្មារតី និងអារម្មណ៍។ ការអនុវត្តល្អបំផុត រួមមាន ការផ្ទេរសាច់ប្រាក់ទៅគ្រួសារទាំងឡាយដែលមានកូន ដែលមានប្រសិទ្ធភាពក្នុងការការពារសិទ្ធិរបស់កុមារ។
- ការអនុវត្តល្អរបស់រដ្ឋាភិបាលនានា វិស័យសាធារណៈ និងវិស័យឯកជន អង្គការជាតិ និងអន្តរជាតិ ដើម្បីកាត់បន្ថយទាំងផលប៉ះពាល់សេដ្ឋកិច្ចសង្គមអវិជ្ជមាននៃវិបត្តិនេះ។
- សុខភាព និងសុវត្ថិភាពការងាររបស់អ្នកដែលធ្វើការក្នុងអំឡុងពេលមានវិបត្តិនេះ ជាពិសេសបុគ្គលិកសុខាភិបាល និងបុគ្គលិកគាំទ្រ ដែលភាគច្រើនជាស្ត្រី គួរតែត្រូវបានគេវាយតម្លៃ និងដោះស្រាយ។ បុគ្គលិកសុខាភិបាល និងអ្នកផ្សេងទៀត ដែលធ្វើការក្នុងបរិស្ថានប្រឈមនឹងហានិភ័យ គួរតែត្រូវបានផ្តល់ជូននូវឧបករណ៍ការពារផ្ទាល់ខ្លួនដែលមានគុណភាព តាមតម្រូវការ។ គ្មាននរណាម្នាក់ គួរមានអារម្មណ៍បង្ខំឱ្យធ្វើការក្នុងលក្ខខណ្ឌដែលមិនចាំបាច់ ធ្វើឱ្យគ្រោះថ្នាក់ដល់សុខភាពរបស់ពួកគេឡើយ ព្រោះពួកគេខ្លាចបាត់បង់ការងារ ឬប្រាក់ខែ។
- ការជម្រុញសារពើពន្ធ និងកញ្ចប់គាំពារសង្គម ដែលមានគោលដៅផ្ទាល់ចំពោះអ្នកដែលអាចលទ្ធភាពតិចតួចបំផុតគឺចាំបាច់ដើម្បីកាត់បន្ថយផលវិបាកដ៏ធ្ងន់ធ្ងរនៃជំងឺរាតត្បាត។ វិធានការបន្ទាន់ជួយសង្គ្រោះសេដ្ឋកិច្ច ដូចជាការឈប់សម្រាកឈឺដែលធានារក្សាប្រាក់ឈ្នួល អត្ថប្រយោជន៍នៅរក្សាឱ្យមាននៅក្នុងអំឡុងពេលឥតការងារធ្វើ ការចែកចាយស្បៀងអាហារ ការថែទាំកុមារ និងប្រាក់ចំណូលសកលជាមូលដ្ឋាន អាចជួយធានាការពារទប់ទល់នឹងផលប៉ះពាល់ធ្ងន់ធ្ងរនៃវិបត្តិ។